# ព្រះគម្ពីរជាភាសាស្វាហ៊ីលី

ដោយ ខាលលី ឡេយ៍

*ដំណើររឿងពិតមកពីប្រទេសអូស្ត្រាលី*

យ៉ាមេឌ បានដើរចូលទៅថ្នាក់សាលាថ្ងៃអាទិត្យ ហើយបានអង្គុយចុះជាមួយមិត្តរួមថ្នាក់របស់គាត់ ។ គាត់បានសម្គាល់ឃើញក្មេងប្រុសម្នាក់ដែលគាត់មិនស្គាល់ បានចូលមកក្នុងថ្នាក់ ហើយអង្គុយចុះឆ្ងាយពីគាត់ពីរបីកៅអី ។

គ្រូរបស់យ៉ាមេឌ គឺបងប្រុសឌ្រូជិន បានញញឹមមកកាន់សិស្សក្នុងថ្នាក់ ។ គាត់បាននិយាយថា « នេះគឺអេម៉ាញ៉ូអែល » ។ « គាត់ និងគ្រួសាររបស់គាត់ទើបតែផ្លាស់មកនៅប្រទេសអូស្ត្រាលី ។ នេះគឺជាអាទិត្យដំបូងរបស់គាត់នៅវួដរបស់យើង ! »

យ៉ាមេឌបានគិតថា វាអាចជារឿងដ៏ពិបាកដើម្បីទៅវួដថ្មីមួយ ។ គាត់នឹងព្យាយាមធ្វើជាមិត្តរបស់អេម៉ាញ៉ូអែល ។

បងប្រុសឌ្រូជិន បានយកព្រះគម្ពីររបស់គាត់ចេញមក ។ គាត់បាននិយាយថា « ចូរយើងបើកទៅគម្ពីរ នីហ្វៃទី៣ » ។

យ៉ាមេឌបានបើកព្រះគម្ពីររបស់គាត់ ហើយក្រឡេកមើលទៅអេម៉ាញ៉ូអែល ។ គាត់ពុំមានព្រះគម្ពីរទេ ។

យ៉ាមេឌបានញញឹមយ៉ាងស្រស់ទៅកាន់គាត់ ហើយខិតកៀកទៅរកគាត់ ។ គាត់បាននិយាយថា « សួស្ដី ខ្ញុំឈ្មោះ យ៉ាមេឌ » ។ « តើចង់មើលព្រះគម្ពីរជាមួយខ្ញុំទេ ? »

អេម៉ាញ៉ូអែលបានញញឹមតបវិញ ។ គាត់បាននិយាយថា « អឺ ! ខ្ញុំមិនសូវចេះភាសាអង់គ្លេសទេ » ។ « សុំទោស » ។

« តើឯងនិយាយភាសាអ្វីដែរ ? »

« ភាសាស្វាហ៊ីលី » ។

យ៉ាមេឌមិនចេះភាសាស្វាហ៊ីលីសូម្បីតែបន្តិចសោះ ។ គាត់ និងអេម៉ាញ៉ូអែលមិនបាននិយាយគ្នាច្រើនទៀតទេរហូតដល់ពេលរៀនចប់ ។

ល្ងាចនោះនៅអាហារពេលល្ងាច យ៉ាមេឌបានប្រាប់គ្រួសាររបស់គាត់អំពីអេម៉ាញ៉ូអែល ។

យ៉ាមេឌបាននិយាយថា « អេម៉ាញ៉ូអែលមើលទៅជាមនុស្សល្អណាស់ » ។ « ប៉ុន្តែយើងមិនអាចយល់គ្នាច្បាស់នោះទេ » ។





យ៉ាមេឌបានគិតថា ខ្ញុំសង្ឃឹមថាមានកិច្ចការដែលខ្ញុំអាចជួយបាន ។

ម៉ាក់បានងក់ក្បាល ។ ម៉ាក់បាននិយាយថា « អេម៉ាញ៉ូអែល និងគ្រួសាររបស់គាត់បានកំពុងជួបទុក្ខលំបាកមួយចំនួននាពេលថ្មីៗនេះ » ។ « ពួកគេត្រូវចាកចេញពីប្រទេសរបស់ពួកគេភ្លាមៗដោយសារតែរឿងរ៉ាវអាក្រក់ៗបានកើតឡើងនៅទីនោះ ។ ពួកគេត្រូវទុកអ្វីៗទាំងអស់ចោល » ។

យ៉ាមេឌបានជ្រួញចិញ្ចើម ។ តើនឹងមានអារម្មណ៍បែបណាទៅ ដែលត្រូវចាកចេញពីផ្ទះនៅថ្ងៃស្អែក ហើយត្រូវរើទៅប្រទេសថ្មីមួយនោះ ? នោះនឹងពិតជាពិបាកណាស់ !

គាត់បានគិតថា ខ្ញុំសង្ឃឹមថាមានអ្វីម៉្យាងដែលខ្ញុំអាចជួយទៅកាន់អេម៉ាញ៉ូអែល ។ ប៉ុន្តែតើអាចជួយអ្វីទៅ ?

យ៉ាមេឌមិនអាចឈប់គិតអំពីអេម៉ាញ៉ូអែលសោះ កាលគាត់រៀបចំចូលគេង ។ គាត់បានអង្គុយចុះនៅតុរបស់គាត់ដោយមានព្រះគម្ពីរមរមន ហើយអានពីរបីខគម្ពីរ ។ ការអានព្រះគម្ពីរតែងតែធ្វើឲ្យគាត់មានអារម្មណ៍ល្អប្រសើរ ។ យប់នេះ ខគម្ពីរទាំងនោះក៏បានរំឭកគាត់ថា អេម៉ាញ៉ូអែលមិនទាន់មានព្រះគម្ពីរជាភាសាស្វាហ៊ីលីទេ ។ យ៉ាមេឌបានបិទព្រះគម្ពីររបស់គាត់ ហើយសម្លឹងមើលក្របគម្ពីរ ។ បន្ទាប់មក គាត់បានលោតពីកៅអីរបស់គាត់ ហើយរត់យ៉ាងលឿនទៅកាន់ច្រកផ្លូវ ។

គាត់បានហៅ « ម៉ាក់ ! » « ខ្ញុំគិតថា ខ្ញុំដឹងថាត្រូវធ្វើយ៉ាងម៉េចដើម្បីជួយអេម៉ាញ៉ូអែលហើយ ! »

នៅសប្ដាហ៍បន្ទាប់ យ៉ាមេឌអន្ទះសាចង់ជួបអេម៉ាញ៉ូអែល ។ គាត់បានអង្គុយជាមួយឌីកុនផ្សេងទៀតនៅខាងមុខនៃសាលាប្រជុំ ហើយរង់ចាំដោយមានព្រះគម្ពីរមរមនថ្មីមួយក្បាលនៅលើភ្លៅរបស់គាត់ ។ ពួកអ្នកផ្សព្វផ្សាយសាសនាបានជួយគាត់ឲ្យទទួលបានព្រះគម្ពីរច្បាប់ពិសេសនេះសម្រាប់អេម៉ាញ៉ូអែល ។

នៅពេលអេម៉ាញ៉ូអែលចូលទៅក្នុងសាលាប្រជុំជាមួយគ្រួសាររបស់គាត់ យ៉ាមេឌបានញញឹម ហើយគ្រវីដៃដាក់គាត់ ។ អេម៉ាញ៉ូអែលមើលទៅច្របូកច្របល់ កាលគាត់អង្គុយចុះក្បែរយ៉ាមេឌ ។ ប៉ុន្តែគាត់បានបើកភ្នែកធំៗ នៅពេលយ៉ាមេឌបានហុចព្រះគម្ពីរមរមនឲ្យគាត់ ។

« សម្រាប់ខ្ញុំមែនទេ ? » អេម៉ាញ៉ូអែលបានសួរ ។

យ៉ាមេឌបានងក់ក្បាល ។

អេម៉ាញ៉ូអែលសប្បាយចិត្តយ៉ាងខ្លាំង ។ គាត់បានបើកមើលទំព័រនៃព្រះគម្ពីរមរមនថ្មីរបស់គាត់ ។ គាត់បាននិយាយថា « នេះជាភាសាស្វាហ៊ីលី ! » ។ គាត់បានញញឹមទៅកាន់យ៉ាមេឌ ហើយឱបព្រះគម្ពីរមរមនជាប់នឹងទ្រូងរបស់គាត់ ។ « អរគុណឯងណាស់ ! »

ដួងចិត្តរបស់យ៉ាមេឌ បានពោរពេញដោយភាពកក់ក្ដៅកាលគាត់ញញឹមតបវិញ ។ គាត់បានដឹងថាគាត់មិនអាចធ្វើឲ្យអ្វីៗទាំងអស់ប្រសើរឡើងសម្រាប់អេម៉ាញ៉ូអែលនោះទេ ហើយពួកគេនៅតែមិនអាចនិយាយយល់គ្នាបានច្បាស់នៅឡើយ ។ ប៉ុន្តែនេះមិនអីនោះទេ ។ ពួកគេមិនចាំបាច់ទាល់តែនិយាយភាសាដូចគ្នាដើម្បីក្លាយជាមិត្តភក្តិឡើយ !



« ចិត្តក្តួលអាណិត គឺជាគុណលក្ខណៈនៃព្រះគ្រីស្ទ ។ វាកើតចេញពីក្តីស្រឡាញ់ចំពោះមនុស្សដទៃ ហើយគ្មានដែនកំណត់ទេ » ។

អែលឌើរ អ៊ឹអាន អេស អាឌិន ក្នុងពួកចិតសិបនាក់ « ស្រឡាញ់អ្នកជិតខាងដូចខ្លួនឯង » *លីអាហូណា* ខែវិច្ឆិកា ឆ្នាំ២០២៣ ទំព័រ ២៤ ។